# ចាប់ផ្តើមជាមួយអ្នកផ្តល់សេវាថ្មីរបស់អ្នក

## ចាប់ផ្តើមឡើងជាមួយជំហានត្រឹមត្រូវ

ក្នុងអំឡុងពេលកិច្ចប្រជុំលើកដំបូងរបស់អ្នកជាមួយអ្នកផ្តល់សេវាថ្មី វាជាការសំខាន់ក្នុងការប្រាប់ពួកគេអំពីអ្វីដែលអ្នករំពឹងទុក។ យកល្អគួរតែនិយាយអំពីបញ្ហាលំបាកណាមួយ ហើយយល់ព្រមលើរឿងអ្វីៗ នៅមុនពេលគាត់ចាប់ផ្តើមធ្វើការងារ។

រឿងមួយចំនួនដែលអ្នកប្រហែលជាចង់និយាយជាមួយអ្នកផ្តល់សេវារបស់អ្នកមានរាយនៅខាងក្រោម។

## ការត្រួតពិនិត្យកិច្ចការដែលមានការអនុញ្ញាត

ពន្យល់ពីកិច្ចការដែលអ្នកផ្តល់សេវានឹងធ្វើសំរាប់អ្នក និងរយៈពេលប៉ុន្មានដែលគាត់អាចប្រើលើកិច្ចការនីមួយៗ ។ ខោនធីនឹងផ្ញើឱ្យអ្នកនូវបញ្ជីរាយឈ្មោះកិច្ចការដែលមានការអនុញ្ញាត និងរយៈពេលដែលបានអនុញ្ញាត នៅពេលពួកគេយល់ព្រម ឬផ្លាស់ប្តូរម៉ោងរបស់អ្នក។ ត្រូវប្រាកដថា អ្នកប្រាប់ទៅអ្នកផ្តល់សេវារបស់អ្នកពីរបៀបដែលអ្នកចង់ឱ្យគាត់ធ្វើកិច្ចការ។

## បញ្ហាសុខភាព

ប្រាប់អ្នកផ្តល់សេវារបស់អ្នកអំពីអាឡែរហ្សី តម្រូវការរបបអាហារពិសេស និងបញ្ហាផ្សេងៗទៀតដែលអ្នកត្រូវការការថែទាំពិសេស។

## ជំងឺដែលឆ្លង (មេរោគ)

វាជាការល្អបំផុតសម្រាប់អ្នក និងអ្នកផ្តល់សេវារបស់អ្នកក្នុងការប្រាប់គ្នាទៅវិញទៅមកថាតើអ្នកទាំងពីរមានជំងឺឆ្លងណាមួយ រួមទាំងមេរោគអេដស៍ ជំងឺរលាកថ្លើម របេង (TB) និង ជំងឺៗផ្សេងៗទៀត។

## គ្រឿងផ្គត់ផ្គង់

បង្ហាញអ្នកផ្តល់សេវាកន្លែងដែលគ្រឿងផ្គត់ផ្គង់ត្រូវបានរក្សាទុក និងរបៀបប្រើប្រាស់ឧបករណ៍ពិសេសណាមួយឱ្យបានត្រឹមត្រូវ។

## ការប្រើថ្នាំ (ឱសថ)

ពន្យល់ពីជំនួយដែលអ្នកត្រូវការ ប្រសិនបើមាន ហើយមើលមួយត្រួស និងប្រាប់ដល់អ្នកផ្តល់សេវា ពីកាលវិភាគថ្នាំប្រចាំថ្ងៃរបស់អ្នក។

## ព័ត៌មានសំរាប់គ្រាមានអាសន្ន

ផ្តល់ព័ត៌មានទាំងអស់ដែលអ្នកផ្តល់សេវារបស់អ្នកត្រូវការ ដើម្បីឱ្យគាត់ដឹងប្រសិនបើមានភាពអាសន្នកើតឡើង។ រួមមានទាំងអ្នកដែលត្រូវហៅទូរស័ព្ទទៅ ក្នុងករណីមានអាសន្ន និងរបៀបចេញពីផ្ទះ។ បិទក្រដាសព័ត៌មានក្នុងគ្រាមានអាសន្ន នៅកន្លែងដែលងាយស្រួលមើលគ្រប់ពេល។

IHSS
IN-HOME SUPPORTIVE SERVICES

CDSS

## កាលវិភាគការងារ

ត្រូវឱ្យច្បាស់ថាតើថ្ងៃណាដែលអ្នកផ្តល់សេវារបស់អ្នកនឹងមក ហើយតើគាត់នឹងធ្វើការប៉ុន្មានម៉ោងក្នុងមួយថ្ងៃ។ យល់ព្រមលើវិធីមួយដើម្បីតាមដានចំនួនម៉ោង ដូច្នេះអ្នកអាចប្រាកដថាទំព័រកត់ត្រាពេលម៉ោងធ្វើការត្រូវបានបំពេញយ៉ាងត្រឹមត្រូវ និងដើម្បីជៀសវាងការបំពានលើទំព័រកត់ត្រាពេលម៉ោងធ្វើការ ដែលអាចបណ្តាលឱ្យអ្នកបាត់បង់អ្នកផ្តល់សេវា។ គួរពិចារណាលើការប្រើប្រាស់ប្រតិទិន ឬក្រដាសកត់ចំណាំ ដើម្បីតាមដានកិច្ចការ និងម៉ោងធ្វើការជារៀងរាល់ថ្ងៃ។

## ព័ត៌មានទំនាក់ទំនង

ផ្តល់ទៅវិញទៅមកនូវលេខទូរស័ព្ទទាំងអស់ដែលអ្នកអាចទាក់ទងបាន និងពេលវេលាដ៏ល្អបំផុតសម្រាប់អ្នកក្នុងការទាក់ទងគ្នាទៅវិញទៅមក។

## យានជំនិះ

កម្មវិធី IHSS មិនបង់ប្រាក់សម្រាប់ថ្លៃសាំង ការធានារ៉ាប់រងលើរថយន្ត ឬយានសម្រាប់ដឹកនាំសាធារណៈទេ។ ត្រូវធ្វើឱ្យប្រាកដថា អ្នកច្បាស់ថាអ្នកណានឹងបង់ថ្លៃទាំងនេះ ហើយអ្នកផ្តល់សេវារបស់អ្នកមានការធានារ៉ាប់រងលើរថយន្ត និងប័ណ្ណបើកបរដែលមានសុពលភាព។

**សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យខោនធីផ្នែក IHSS ក្នុងតំបន់របស់អ្នក។**